# ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់

## ការចូលរួមរបស់អង្គការសង្គមស៊ីវិល

- អង្គការសង្គមស៊ីវិលទូទៅ
- អង្គការមិនមែនរដ្ឋាភិបាល
- ស្ថាប័នសិទ្ធិមនុស្សជាតិ
- អ្នកការពារសិទ្ធិមនុស្ស
- សមាគមនៅតាមមូលដ្ឋាន
- អង្គការនៅតាមមូលដ្ឋាន
- សហជីព
- ក្រុមនិងអង្គការដទៃទៀតដែលតាមធម្មតាមិនចូលរួមជាមួយអង្គការសហប្រជាជាតិ

ក្រុមនានាត្រូវបានលើកទឹកចិត្តឱ្យដាក់បញ្ជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅក្នុងរបាយការណ៍ភាគីពាក់ព័ន្ធដែលត្រូវយកមកពិចារណាក្នុងពេលត្រួតពិនិត្យ។

តាមរយៈរបាយការណ៍នានារបស់ខ្លួន អង្គការសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឱ្យលើកនូវសំណើជាអនុសាសន៍នានា និងអាចលើកឡើងជាថ្មីនូវអនុសាសន៍ណាមួយពីមុនដែលពាក់ព័ន្ធ។

ភាគីពាក់ព័ន្ធដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ក៏អាចចូលរួមនិងអង្កេតលើក្រុមការងារ យូភីអ ផងដែរ។ អង្គការសង្គមស៊ីវិលមិនត្រូវបានអនុញ្ញាតឱ្យថ្លែងមតិយោបល់ទេក្នុងអំឡុងពេលត្រួតពិនិត្យ ប៉ុន្តែពួកគេអាចមានវត្តមានក្នុងបន្ទប់ប្រជុំបាន។

ក្នុងអំឡុងពេលអនុម័តរបាយការណ៍របស់ក្រុមការងារ យូភីអ នៅក្នុងកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិលត្រូវបានផ្តល់ឱកាសឱ្យធ្វើសេចក្តីថ្លែងការណ៍រយៈពេល ២០ នាទី។

បន្ទាប់ពីការត្រួតពិនិត្យ អង្គការសង្គមស៊ីវិលអាចជួយ និងសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តអនុសាសន៍ ព្រមទាំងតាមដានការអនុវត្ត ហើយនិងរាយការណ៍អំពីការអនុវត្តអនុសាសន៍ដែលរដ្ឋបានទទួលយក។

## ហេតុអ្វីបានជាអង្គការសង្គមស៊ីវិលត្រូវចូលរួម?

1. អង្គការសង្គមស៊ីវិលអាចមានឥទ្ធិពលលើលទ្ធផលនៃការត្រួតពិនិត្យ។
2. របាយការណ៍របស់ពួកគេផ្តល់នូវមូលដ្ឋានមួយសម្រាប់ការតស៊ូមតិ ដល់រដ្ឋដែលផ្តល់អនុសាសន៍នៅមុនកិច្ចសន្ទនាអន្តរកម្ម។
3. អង្គការសង្គមស៊ីវិលលើកឡើងនូវការវាយតម្លៃរបស់ខ្លួនទៅលើស្ថានភាពសិទ្ធិមនុស្សដោយធ្វើការប្រៀបធៀបជាមួយនឹងរបាយការណ៍ជាតិ។
4. អង្គការសង្គមស៊ីវិលដើរតួនាទីសំខាន់ក្នុងការតាមដានលើការអនុវត្តអនុសាសន៍ ដែលជាការបង្កើននូវលទ្ធផលវិជ្ជមាននៃ យូភីអ ព្រមទាំងជាការលើកកម្ពស់ការអនុម័តនូវគោលនយោបាយសិទ្ធិមនុស្សល្អប្រសើរនានា។


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org


CC BY NC SA